00191059

ការបាន C 33

ឯកសារបានចំលងត្រឹមត្រូវតាមច្បាប់ដើម
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date/Date de certification):
21 / 05 / 2008
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: CHEA Kosal

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Royaume du Cambodge
Nation Religion Roi

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception):
21 / 05 / 2008
ម៉ោង (Time/Heure): 09 h 40
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: CHEA Kosal

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Chambres Extraordinaires au sein des Tribunaux Cambodgiens

ការិយាល័យសហចៅក្រមស៊ើបអង្កេត
**Office of the Co-Investigating Judges**
**Bureau des Co-juges d'instruction**

សំណុំរឿងព្រហ្មទណ្ឌ
**Criminal Case File /Dossier pénal**
**លេខ/No: 002/14-08-2006**

**លេខស៊ើបសួរ/Investigation/Instruction**
**លេខ/No: 002/19-09-2007-ECCC-OCIJ**

# ដីកាសម្រេចលើលក្ខខណ្ឌនៃការឃុំខ្លួន
# Ordonnance sur les conditions de détention provisoire
# Order concerning Provisional Detention Conditions

យើង **យូ ប៊ុនឡេង** និង Marcel Lemonde (ម៉ាសែល ឡឺម៉ុង) សហចៅក្រមស៊ើបអង្កេតនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

បានឃើញច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញ ចុះថ្ងៃទី ២៧ ខែតុលា ឆ្នាំ២០០៤

បានឃើញវិធាន ៥៥(៥) និងវិធាន ៦៣ នៃវិធានផ្ទៃក្នុងនៃអង្គជំនុំជម្រះវិសាមញ្ញ

បានឃើញការបើកការស៊ើបសួរលើ៖

**នួន ជា** និងអ្នកដទៃ

ត្រូវបានដាក់អោយស្ថិតក្រោមការពិនិត្យចំពោះបទឧក្រិដ្ឋប្រឆាំងនឹងមនុស្សជាតិ និងការរំលោភបំពានធ្ងន់ធ្ងរលើសន្ធិសញ្ញាទីក្រុងហ្សឺណែវ ចុះថ្ងៃទី ១២ ខែសីហា ឆ្នាំ១៩៤៩ បទល្មើសដែលមានចែង និងផ្តន្ទាទោសតាមមាត្រា ៥ មាត្រា ៦ មាត្រា ២៩ (ថ្មី) និងមាត្រា ៣៩ (ថ្មី) នៃច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញ ចុះថ្ងៃទី ២៧ ខែតុលា ឆ្នាំ២០០៤



អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានទីតាំងស្ថិតនៅ ផ្លូវជាតិលេខ៤ សង្កាត់ ចោមចៅ ខណ្ឌ ដង្កោ ក្រុង ភ្នំពេញ ប្រអប់សំបុត្រលេខ៧១ ទូរស័ព្ទលេខ +៨៥៥(០)២៣ ២១៨៩១៤ ទូរសារលេខ +៨៥៥(០)២៣ ២១៨៩៤១។
Extraordinary Chambers in the Courts of Cambodia National Road 4, Choam Chao, Dangkoa Phnom Penh
Mail Po Box 71, Phnom Penh Tel:+855(0)23 218914 Fax: +855(0) 23 218941.
Chambres extraordinaires au sein des tribunaux cambodgiens, Route nationale 4, Choam Chao, Dangkoa, Phnom Penh
Boite postale 71, Phnom Penh. Tel: +855(0)23 218914 Fax: +855(0) 23 218941.

ECCC * CETC * CO-INVESTIGATING JUDGES * CO-JUGES D'INSTRUCTION

បានឃើញពាក្យសុំរបស់មេធាវីជនជាប់ឃុំ **នួន ជា** និង **អៀង ធីរិទ្ធ** ចុះថ្ងៃទី ១៤ និងថ្ងៃទី ២៥ ខែមីនា ឆ្នាំ ២០០៨

បានឃើញសេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះ ចុះថ្ងៃទី ៣០ ខែមេសា ឆ្នាំ ២០០៨ លើបណ្តឹងឧទ្ធរណ៍របស់ជនជាប់ឃុំ **អៀង សារី**

បានឃើញអនុស្សរណៈផ្ទៃក្នុងរបស់យើងចុះថ្ងៃទី ៨ ខែឧសភា ឆ្នាំ ២០០៨ ទាក់ទិននឹងការជួបរវាង ជនជាប់ឃុំ **អៀង សារី** និងជនជាប់ឃុំ **អៀង ធីរិទ្ធ**

បានឃើញអំពីភាពចន្លោះនៃបទបញ្ជាច្បាស់លាស់នៃលក្ខខណ្ឌពិតប្រាកដនៃការឃុំខ្លួនជនត្រូវចោទ និងជាពិសេសការមិនទាន់ចូលជាធរមាននៃសេចក្តីព្រាងនៃបទបញ្ជាស្តីពីគ្រប់គ្រងមន្ទីរឃុំឃាំងរបស់អង្គជំនុំជម្រះវិសាមញ្ញ

យល់ឃើញថាគឺជាការចាំបាច់ដែលត្រូវបញ្ជាក់ពីមូលហេតុនៃការដាក់ឱ្យនៅដាច់ដោយឡែកពីគ្នារវាងជនដែលជាប់ឃុំ និងដែលចេញពីនេះកំណត់ពីលក្ខខណ្ឌនៃការឃុំខ្លួនដូចតទៅ៖

**<u>មូលហេតុនៃសេចក្តីសម្រេច</u>**

ក) ការដាក់ឲ្យនៅដាច់ដោយឡែកពីគ្នារវាងសហជនជាប់ឃុំ

១) ជាបឋម វាជាការសំខាន់ដែលត្រូវរំលឹកថា ជនត្រូវចោទត្រូវបានចោទប្រកាន់ពីបទឧក្រិដ្ឋដែលមានលក្ខណៈធ្ងន់ធ្ងរ និងស្មុគ្រស្មាញ ហើយដែលអាចទទួលខុសត្រូវជាបុគ្គល ឬរួមគ្នាចំពោះបទល្មើសជាច្រើនដែលបានប្រព្រឹត្តនៅលើទឹកដីកម្ពុជាទាំងមូលក្នុងរយៈពេល ៣ឆ្នាំ ៨ខែ និង ២០ថ្ងៃ។

២)ម្យ៉ាងទៀត យុត្តិសាស្ត្រអន្តរជាតិ ជាពិសេសតុលាការអឺរ៉ុបសម្រាប់សិទ្ធិមនុស្ស (CEDH) ទទួលស្គាល់យ៉ាងច្បាស់ថាការឃុំខ្លួនមុនពេលជំនុំជម្រះ អាចត្រូវបានធ្វើឡើង ទៅតាមតម្រូវការចាំបាច់មួយក្នុងចំណោមតម្រូវការចាំបាច់ដទៃទៀតគឺរារាំងកុំឱ្យមានការឃុបឃិតគ្នារវាងសហជនជាប់ចោទ[1]។ ដូចជា នៅក្នុងសេចក្តីសម្រេច *Bąk ប្រឆាំងនឹង Poland* បញ្ជាក់ថា (កថាខ័ណ្ឌ ៥៦)៖ *"តុលាការកត់សំគាល់ឃើញថា ករណីរឿងក្តីនេះ (...) គឺជាឧទាហរណ៍យ៉ាងសាមញ្ញមួយ*

[1] ជាឧទាហរណ៍ សូមអាន *W. v. Switzerland*, judgment of 26 January 1993, Series A no. 254-A, p. 15, § 35; Gérard Bernard c. France, no. 27678/02, ថ្ងៃទី ២៦ ខែកញ្ញា ឆ្នាំ ២០០៦; *Bąk v. Poland*, no. 7870/04, § 57, ថ្ងៃទី ១៦ ខែមករា ឆ្នាំ ២០០៧, paras. 56-60; និង *Łaszkiewicz v. Poland*, no. 28481/03, ថ្ងៃទី ១៥ ខែមករា ឆ្នាំ ២០០៨, para. 59។





CO-INVESTIGATING JUDGES * CO-JUGES D'INSTRUCTION * E.C.C.C * C.E.T.C

ការ/N° C 33

*នៃបទឧក្រិដ្ឋដែលមានលក្ខណៈជាអង្គការចាត់តាំង មានន័យថាជាបទឧក្រិដ្ឋដែលការលំបាកច្រើនសម្រាប់អាជ្ញាធរស៊ើបអង្កេត និងបន្ទាប់មកទៀតសម្រាប់តុលាការក្នុងការកំណត់អំពីការពិត និងកម្រិតនៃការទទួលខុសត្រូវរបស់សមាជិកម្នាក់ៗនៃក្រុម។ វាច្បាស់ណាស់ថា រឿងក្តីប្រភេទនេះ ការបន្តត្រួតពិនិត្យមើល ការកំហិតទំនាក់ទំនងក្នុងចំណោមជនត្រូវចោទទាំងនេះ និងជាមួយមនុស្សផ្សេងទៀត អាចជាការចាំបាច់ ដើម្បីជៀសវាងការរត់គេចខ្លួន ការបំបាត់ភស្តុតាង និងសំខាន់ជាងគេបំផុតគឺ ការគាបសង្កត់ ឬក៏ការគំរាមកំហែងលើសាក្សី។ ដូច្នេះ រយៈពេលនៃការឃុំខ្លួនដែលវែងជាងករណីរឿងក្តីផ្សេងទៀត អាចសមហេតុផល"*។ លើសពីនេះទៀត ទោះបីជាគោលការណ៍ការដាក់ជនជាប់ឃុំឲ្យនៅដាច់ដោយឡែកពីគ្នានេះត្រូវបានពិចារណាឡើងវិញជាមួយនឹងពេលវេលាក៏ដោយ ក៏វាច្បាស់ណាស់ថាចំពោះរឿងក្តីបែបនេះ ការដាក់ឲ្យនៅដាច់ដោយឡែកពីគ្នាជាបន្តទៀត មានលក្ខណៈត្រឹមត្រូវ ប្រសិនបើផលប្រយោជន៍នៃការស៊ើបសួរដែលមានលក្ខណៈស្មុគស្មាញមួយ ទាមទារឲ្យធ្វើដូច្នេះ[2]។

២) ប្រាកដណាស់ ការលើកសំអាងហេតុផលនេះអនុវត្តជាពិសេសទៅទៀតទៅលើទិដ្ឋភាពពីរនៃហេតុផលទីមួយ ដែលមានលក្ខណៈបំពេញ ឬបង្គ្រប់គ្នាទៅវិញទៅមក ដែលវិធានផ្ទៃក្នុងមិនបានញែកចេញពីគ្នា៖ វាច្បាស់ណាស់ថា ដោយគិតអំពីហានិភ័យនៃការគាបសង្កត់ទៅលើសាក្សី ឬជនរងគ្រោះ សហចៅក្រមស៊ើបអង្កេតបានពិចារណាឃើញយ៉ាងងាយថា សម្រាប់ជនត្រូវចោទទាំងបួនរូប ពួកគេមិនអាចប្រាស្រ័យទាក់ទងគ្នាទៅវិញទៅមកបានទេ ហើយការត្រូវរូវគ្នាប្រាកដជាធ្វើឲ្យការគាបសង្កត់ទៅលើសាក្សីរឹតតែមានភាពងាយស្រួលឡើង បើគិតពីបណ្តាញឥទ្ធិពលរបស់ជនជាប់ចោទម្នាក់ៗ។

៣) សេចក្តីសម្រេចដាច់តែឯងមួយដែលចេញដោយអង្គបុរេជំនុំជម្រះរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ (CPI) នៅក្នុងរឿងក្តី*រដ្ឋអាជ្ញាប្រឆាំងនឹង Germain Kantaga និងMathieu Ngudjolo Chui* មិនធ្វើឲ្យប៉ះពាល់ដល់ភាពត្រឹមត្រូវនៃការលើកសំអាងហេតុផលខាងលើនេះទេ[3]។ តាមពិត សេចក្តីសម្រេចចុះថ្ងៃទី ១៣ ខែមីនា ឆ្នាំ ២០០៨ ដែលអនុញ្ញាតយល់ព្រមឲ្យសហជនជាប់ចោទនូវ *"សិទ្ធិពិភាក្សាគ្នាពីធាតុទាំងឡាយនៃភស្តុតាង (...) ដើម្បីរៀបចំការការពារខ្លួនបានល្អត្រឹមត្រូវ"* គឺសំអាងលើការមិនមានភស្តុតាងជាក់ស្តែងដែលបង្ហាញថា សហជនជាប់ចោទទាំងនេះ បានព្រមព្រៀងគ្នាក្នុងការផ្តល់សក្ខីកម្ម ឬភស្តុតាងមិនពិត ហេតុដូច្នេះវាអាចធ្វើឲ្យខូចទៅដល់នីតិវិធីធ្វើឡើងប្រឆាំងនឹងពួកគេបាន។ តែបើយោងទៅតាមយុត្តិសាស្ត្ររបស់តុលាការអឺរ៉ុបសម្រាប់សិទ្ធិមនុស្ស ដែលបានលើកឡើងនៅក្នុងកថាខណ្ឌខាងលើវិញ

---

[2] *Kemmache v. France* សាលក្រមថ្ងៃទី ២៧ ខែវិច្ឆិកា ឆ្នាំ ១៩៩១, Series A no. 218, para. 54; *Muller v. France* សាលក្រមថ្ងៃទី ១៧ ខែមីនា ឆ្នាំ ១៩៩៧, របាយការណ៍អំពីសាលក្រម និងសេចក្តីសម្រេច ១៩៩៧-II, para. 40; និងសូមអាន, Górski v. Poland, no. 28904/02, § 58, ថ្ងៃទី ៤ ខែតុលា ឆ្នាំ ២០០៥។

[3] ICC-01/04-01/07

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានទីតាំងស្ថិតនៅ ផ្លូវជាតិលេខ៤ សង្កាត់ ចោមចៅ ខណ្ឌ ដង្កោ ក្រុង ភ្នំពេញ ប្រអប់សំបុត្រលេខ៧១ ទូរស័ព្ទលេខ +៨៥៥(០)២៣ ២១៨៩៤១ ទូរសារលេខ +៨៥៥(០)២៣ ២១៨៩៤១។
Extraordinary Chambers in the Courts of Cambodia National Road 4, Choam Chao, Dangkoa Phnom Penh
Mail Po Box 71, Phnom Penh Tel:+855(0)23 218914 Fax: +855(0) 23 218941.
Chambres extraordinaires au sein des tribunaux cambodgiens, Route nationale 4, Choam Chao, Dangkoa, Phnom Penh
Boite postale 71, Phnom Penh. Tel: +855(0)23 218914 Fax: +855(0) 23 218941.



E.C.C.C * C.E.T.C * CO-INVESTIGATING JUDGES * CO-JUGES D'INSTRUCTION

ការឃុំខ្លួនបណ្តោះអាសន្ន និងលក្ខខណ្ឌនានាជាប់ពាក់ព័ន្ធនឹងការឃុំខ្លួន មិនអាចសំអាងតែទៅលើភស្តុតាងនៃការប្រព្រឹត្ត ជាក់លាក់ប៉ុណ្ណោះទេ៖ ផ្ទុយទៅវិញ ចំនុចតែមួយគត់ដែលត្រូវយកមកពិចារណាគឺ ការវាយតម្លៃពីហានិភ័យ។ ម្យ៉ាងទៀត អង្គបុរេជំនុំជម្រះរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ នៅក្នុងរឿងក្តីដដែលនេះ បានចេញសេចក្តីសម្រេចថ្មីមួយទៀតដែល ខុសគ្នាយ៉ាងខ្លាំង ពីព្រោះចាត់ទុកការឃុំខ្លួន Germain Kantaga ថាជាការត្រឹមត្រូវដោយហេតុផលថា ការឃុំខ្លួននេះ គឺជាការចាំបាច់ដើម្បីធានាថាជននេះ នឹងមិនបង្កជាឧបសគ្គ ឬនឹងធ្វើឲ្យប៉ះពាល់ដល់កិច្ចស៊ើបសួរកំពុងដំណើរការ។

៤) ជាបន្តទៀត គួររំលឹកថា នៅក្នុងសេចក្តីសម្រេចរបស់ខ្លួនចុះថ្ងៃទី ២០ ខែមីនា ឆ្នាំ ២០០៨ លើបណ្តឹងឧទ្ធរណ៍របស់ **នួន ជា** ទាក់ទិននឹងការឃុំខ្លួនបណ្តឹងអាសន្ន អង្គបុរេជំនុំជម្រះរបស់ អ.វ.ត.ក បានពន្យល់ (កថាខណ្ឌ ៥៩) ថា ហេតុផលទីមួយ និងទីពីរ ដែលមានចែងនៅក្នុងវិធាន ៦៣(៣)(ខ)[4] នៃវិធានផ្ទៃក្នុងនៃ អ.វ.ត.ក អាចត្រូវបានពិនិត្យរួមគ្នា "ពីព្រោះហេតុផលទាំងពីរនេះ សំអាងលើទឡ្ហីករណ៍ដូចគ្នា"។

៥) វាជាការពិតដែលថា ពេលវេលាបានកន្លងផុតអស់រយៈពេលប្រមាណ ៣០ ឆ្នាំហើយ ចាប់តាំងសម័យកាល នៃបទល្មើស រហូតដល់ពេលដែលជាប់ត្រូវចោទត្រូវបានចាប់ខ្លួន ដែលនៅក្នុងចន្លោះពេលវេលានេះ ពួកគេមានឱកាស គ្រប់គ្រាន់ដើម្បីទាក់ទងគ្នាទៅវិញទៅមក។ ប៉ុន្តែទោះជាយ៉ាងណាក៏ដោយក៏ការត្រូវរួវគ្នាដែលអាចកើតមានឡើងមុនពេល ជំនុំជម្រះ ដាច់ខាតមានការកើនឡើង ខណៈពេលជនទាំងនេះត្រូវបានចាប់ខ្លួន និងត្រូវបានចោទប្រកាន់៖ ចាប់តាំងពី ពេលនោះមក ពួកគេអាចមើលសំណុំរឿង ដែលមិនត្រឹមតែបង្ហាញពីកម្រិតនៃការទទួលខុសត្រូវលើបទចោទប្រកាន់ ចំពោះពួកគេម្នាក់ៗទៅតាមអង្គហេតុផ្សេងៗគ្នាប៉ុណ្ណោះទេ ប៉ុន្តែវាក៏ប្រាប់ឲ្យសហជនជាប់ចោទទាំងនោះដឹងអំពីទិសដៅ និងខ្លឹមសារនៃកិច្ចស៊ើបសួរផងដែរ។

៦) ដោយផ្អែកលើកត្តាទាំងអស់នេះហើយ ដូច្នេះវាជាការចាំបាច់ដែលត្រូវរក្សាការដាក់ឲ្យនៅដាច់ដោយឡែកពីគ្នារវាង ជនជាប់ឃុំ (លើកលែងតែករណីប្តី-ប្រពន្ធ **អៀង សារី** និង **អៀង ធីរិទ្ធ** ដែលនឹងត្រូវរំលឹកឡើងវិញនៅខាងក្រោមនេះ)។ ជាការពិតក្នុងការអនុវត្តន៍ ដោយសារស្ថានភាពពិសេសនៃមន្ទីរឃុំឃាំងរបស់ អ.វ.ត.ក ការដាក់ឲ្យនៅដាច់ដោយឡែក

[4] អនុលោមតាមវិធាន ៦៣(៣)(ខ) ដីកាឃុំខ្លួនបណ្តោះអាសន្ន អាចត្រូវបានចេញ ប្រសិនបើការឃុំខ្លួនបណ្តោះអាសន្ននោះ គឺជាវិធានការចាំបាច់ដើម្បី៖

*១) រារាំងដើម្បីកុំឲ្យជនត្រូវចោទនោះគាបសង្កត់ទៅលើសាក្សី ឬជនរងគ្រោះ ឬរារាំងកុំឲ្យមានការត្រូវរួវគ្នារវាងជនត្រូវចោទ និងអ្នកសមគំនិតចំពោះបទឧក្រិដ្ឋ ដែលស្ថិតនៅក្រោមយុត្តាធិការរបស់អង្គជំនុំជម្រះវិសាមញ្ញ។*

*២) ថែរក្សាភស្តុតាង ឬការពារមិនឲ្យបំផ្លាញភស្តុតាង។*



ការិយាល័យសហចៅក្រមស៊ើបអង្កេត * E.C.C.C * C.E.T.C * CO-INVESTIGATING JUDGES "CO-JUGES D'INSTRUCTION"

ពីគ្នាបែបនេះ គឺមានន័យជាក់ស្ដែងថាជាការដាក់ជនជាប់ឃុំឱ្យនៅដាច់ពីគេនៅក្នុងទីកន្លែងឃុំឃាំង។ ដូច្នេះ វាជាការចាំបាច់ដែលត្រូវពិនិត្យ ថាតើការដាក់ជនជាប់ឃុំឱ្យនៅដាច់ពីគេបែបនេះ គឺជារំលោភសិទ្ធិជាមូលដ្ឋានមួយចំនួនដូចដែលពួកគេបានលើកឡើង ឬយ៉ាងណា។

## ខ) ការធ្វើបាបបែបអមនុស្សធម៌ និងបែបបន្ថោកបន្ទាប

៧) យោងតាមយុត្តិសាស្ត្រមួយដែលមិនមានការផ្លាស់ប្ដូររបស់តុលាការអឺរ៉ុបសម្រាប់សិទ្ធិមនុស្ស ការដាក់ជនជាប់ឃុំណាម្នាក់ឱ្យនៅដាច់ដោយឡែកពីអ្នកជាប់ឃុំដទៃទៀត (រួមទាំងដើម្បីជៀសវាងការត្រូវរូវគ្នាផង[5]) មិនត្រូវបានចាត់ទុកថាជាការធ្វើបាបបែបអមនុស្សធម៌ទេ[6] ជាពិសេសចំពោះបទឧក្រិដ្ឋដែលមានលក្ខណៈជាអង្គការចាត់តាំង[7]។ ជាការពិតណាស់ មានការសម្រេចដូច្នេះថា ប្រសិនបើពិចារណាឃើញថា "លក្ខខណ្ឌពិសេស ភាពតឹងរឹងនៃវិធានការណ៍ ថេរវេលា គោលដៅដែលចង់បាន ព្រមទាំងផលវិបាកកើតមានឡើងនៃការឃុំឃាំងណាមួយ" នាំឱ្យជនជាប់ឃុំណាម្នាក់មាន "ភាពឯកោខាងផ្លូវអារម្មណ៍ បូកផ្សំជាមួយនឹងភាពនៅឆ្ងាយតែឯងពីសង្គមទាំងស្រុងផង" ករណីនេះអាចចាត់ទុកថាជាការបង្កើតនូវ "ទម្រង់មួយនៃការធ្វើបាបបែបអមនុស្សធម៌ ហើយមិនអាចយកភាពចាំបាច់ផ្នែកសន្តិសុខមកសំអាងបានទេ"[8]។

៨) ករណីខាងលើនេះ ប្រាកដណាស់ថាមិនដូចជាករណីនៅទីនេះទេ។ ជនត្រូវចោទទាំងអស់ ទទួលបាននូវការមកសួរសុខទុក្ខពីសំណាក់សមាជិកក្រុមគ្រួសាររបស់ខ្លួន (កូន ចៅដែលមានអាយុចាប់ពី ១៨ឆ្នាំ ឡើងទៅ និងប្ដី-ប្រពន្ធរបស់ខ្លួន) ជួបជាមួយមេធាវី និងជំនួយការរបស់មេធាវី ព្រមទាំងវេជ្ជបណ្ឌិតទៅតាមការចាំបាច់។

---

[5] G. Ensslin, A. Baader, J. Raspe v. République Fédérale d'Allemagne, សេចក្ដីសម្រេច ថ្ងៃទី ៨ ខែកក្កដា ឆ្នាំ ១៩៧៨, បណ្ដឹងលេខ 7572/76 , 7586/76 et 7587/76, ទំ. 84 ។

[6] *Ilaşcu and Others v. Moldova and Russia* [GC], no. 48787/99, para. 432, ECHR 2004-VII; *Ocalan v. Turkey*, សាលក្រមថ្ងៃទី ១២ ខែឧសភា ឆ្នាំ ២០០៥, ល. 46221/99, para. 191; Ramirez Sanchez v. France, សាលក្រមថ្ងៃទី ៤ ខែ កក្កដា ឆ្នាំ ២០០៦, ល. 59450/00, para. 123 ។

[7] ក្នុងរឿងនេះ សូមអាន រឿងក្ដីនានាប្រឆាំងនឹងប្រទេសអ៊ីតាលី ទាក់ទិននឹង « L'Article 41bis de la loi no. 354 du 26 juillet 175 sur l'administration penitentiaire », ដូចជា Messina (no. 2) c. Italie (dec), no. 25498/94, CEDH 1999-V, *Cavallo c. Italie*, សាលដីកាថ្ងៃទី ៤ ខែមីនា ឆ្នាំ ២០០៨, ល. 6786/03, *Guidi c. Italie*, សាលដីកាថ្ងៃទី ២៧ ខែមីនា ឆ្នាំ ២០០៨, ល. 28320/02, *Argenti c. Italie*, សាលដីកាថ្ងៃទី ១០ ខែកុម្ភៈ ឆ្នាំ ២០០៦, ល. 56317/00 ។

[8] ជាឧទាហរណ៍ សូមអាន G. Ensslin, A. Baader, J. Raspe v. République Fédérale d'Allemagne, op.cit., និង *Ocalan v. Turkey*, op.cit.,





E.C.C.C * C.E.T.C * CO-INVESTIGATING JUDGES * CO-JUGES D'INSTRUCTION

C33

សិទ្ធិទទួលបានការមកសួរសុខទុក្ខក៏ត្រូវបានផ្ដល់ផងដែរដល់អ្នកដែលមិនមែនជាសមាជិកក្រុមគ្រួសារ។ ជនជាប់ឃុំនៅមានសៀវភៅ កាសែត វិទ្យុ និងទូរទស្សន៍ សម្រាប់អាន ស្ដាប់ និងមើលទៀតផង។ ពួកគេមានទំនាក់ទំនងជាធម្មតាជាមួយបុគ្គលិករបស់មន្ទីរឃុំឃាំង និងអាចទាក់ទងជាមួយនឹងមនុស្សខាងក្រៅតាមរយៈទូរស័ព្ទ និងតាមសំបុត្រ។

៩) ហេតុដូច្នេះ គេមិនអាចលើកឡើងថា ការដាក់សហជនជាប់ចោទឲ្យនៅដាច់ពីគ្នា គឺជាការរំលោភលើការហាមឃាត់ការធ្វើបាបបែបអមនុស្សធម៌ និងបែបបន្ថោកបន្ទាបបានទេ។

គ) ជីវិតឯកជន និងជីវិតគ្រួសារ

១០) ដោយគិតពីគោលបំណងស្របច្បាប់នៃការដាក់កំហិត និងភាពច្បាស់លាស់នៃការដាក់កំហិតនេះ ការប៉ះពាល់ដល់សិទ្ធិរបស់ជនជាប់ឃុំមានជីវិតជាឯកជន (រួមទាំងទំនងទំនងជាមួយសង្គមខាងក្រៅផង) និងជីវិតជាលក្ខណៈគ្រួសារមិនអាចត្រូវបានចាត់ទុកថាមិនមានសមាមាត្រនោះទេ បើប្រៀបធៀបទៅនឹងភាពដាច់ខាតនៃការប្រកាន់នូវបូរណភាពនៃកិច្ចស៊ើបសួរ[9] លើកលែងតែករណីទាក់ទិននឹងគ្រួសារប្ដី-ប្រពន្ធ **អៀង សារី** និង **អៀង ធីរិទ្ធ**។

១១) ស្ថានភាពរបស់អ្នកទាំងពីរចុងក្រោយនេះ ត្រូវតែ (និងត្រូវបាន) ទទួលស្គាល់ថាមានលក្ខណៈខុសពីគេ ដោយសារពួកគេគឺជាប្ដី-ប្រពន្ធ។ ហេតុដែលសហចៅក្រមស៊ើបអង្កេត មិនបានអនុញ្ញាតយល់ព្រមនូវសិទ្ធិសួរសុខទុក្ខគ្នាទេ គឺដោយសារតែកិច្ចស៊ើបសួរមួយចំនួន មិនទាន់បានបញ្ចប់[10] ប៉ុន្តែនៅពេលដែលកិច្ចស៊ើបសួរទាំងនេះ ត្រូវបានធ្វើរួចហើយ ពួកគេត្រូវបានអនុញ្ញាតយល់ព្រមឲ្យជួបគ្នានៅក្នុងមន្ទីរឃុំឃាំង ជាដំបូងម្ដងក្នុងមួយសប្ដាហ៍[11] និងក្រោយមកទៀតមួយដងក្នុងមួយថ្ងៃ បន្ទាប់ពីមានសេចក្ដីសម្រេចរបស់អង្គបុរេជំនុំជម្រះចុះថ្ងៃទី ៣០ ខែមេសា ឆ្នាំ ២០០៨[12]៖ ស្ថានភាពជាប្ដី-ប្រពន្ធរបស់ពួកគេ បង្កើតបានជាមូលហេតុមួយគ្រប់គ្រាន់ដើម្បីធ្វើឲ្យមានលំនឹងរវាងផលប្រយោជន៍ដែលផ្ទុយគ្នា

---

[9] ជាពិសេស សូមអាន *Messina c. Italie* (no 2) សាលក្រមថ្ងៃទី ២៨ ខែធ្នូ ឆ្នាំ ២០០០, ល. 25498/94, paras. 61-74, ព្រមទាំងរឿងក្ដីប្រឆាំងនឹងប្រទេសអ៊ីតាលីទាក់ទិននឹង « L'Article 41bis de la loi no. 354 du 26 juillet 175 sur l'administration penitentiaire », op. cit. *Cavallo c. Italie, Guidi c. Italie et Argenti c. Italie*។

[10] សូមអានលិខិតរបស់សហចៅក្រមស៊ើបអង្កេត, A104/I, ចុះថ្ងៃទី ២២ ខែមករា ឆ្នាំ ២០០៨ បដិសេធការកែប្រែលក្ខខណ្ឌនៃការជួបសួរសុខទុក្ខ (ERN 00159511) ។

[11] សូមអានអនុស្សរណៈផ្ទៃក្នុងផ្ញើជូនប្រធានមន្ទីរឃុំឃាំង, A104/III, ចុះថ្ងៃទី ១៧ ខែមីនា ឆ្នាំ ២០០៨។

[12] សូមអានអនុស្សរណៈផ្ទៃក្នុងផ្ញើជូនប្រធានមន្ទីរឃុំឃាំង ចុះថ្ងៃទី ៨ ខែឧសភា ឆ្នាំ ២០០៨។



ECCC * CETC * CO-INVESTIGATING JUDGES * CO-JUGES D'INSTRUCTION

ការអង C 33

ដោយឱ្យមានការជួបគ្នារវាងជនជាប់ឃុំទាំងពីរនេះតាមទម្រង់មួយដែលមានការត្រួតពិនិត្យ។ ម្យ៉ាងទៀត វាអាចបញ្ជាក់បានថា ការជួបគ្នាបែបនេះ អាចចាត់ទុកថាជាទម្រង់មួយនៃការជួបជុំគ្រួសារក៏បាន។

ឃ) ការសន្មតជាមុនថាគ្មានទោស

១២) មេធាវីការពារក្តី អះអាងថា របៀបឃុំខ្លួនដោយដាក់ឱ្យនៅដាច់ដោយឡែកពីគ្នា គឺធ្វើឱ្យមានការប៉ះពាល់ដល់ការសន្មតជាមុនថាគ្មានទោសរបស់ជនជាប់ឃុំ ដែលទទួលរងបែបនេះនូវទម្រង់នៃការដាក់ទណ្ឌកម្ម នៅពេលដែលពួកគេមិនទាន់ត្រូវបានកាត់ទោសពីបទល្មើសណាមួយនៅឡើយ។ ការសំអាងហេតុផលបែបនេះ មិនអាចទទួលយកបានទេ។ ជនត្រូវចោទម្នាក់ៗ បច្ចុប្បន្នត្រូវបានជាប់ឃុំ ដោយផ្អែកទៅលើហេតុផលដែលមានរៀបរាប់នៅក្នុងដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន[13] ស្របតាមសេចក្តីណែនាំរបស់សហចៅក្រមស៊ើបអង្កេតផ្ញើជូនប្រធានមន្ទីរឃុំឃាំង។ ជនជាប់ឃាំងត្រូវបានដាក់ឱ្យនៅដាច់ដោយឡែកពីគ្នា ដោយសារហេតុផលនៃភាពចាំបាច់សម្រាប់ការស៊ើបសួរ ដែលស្របតាមលក្ខខណ្ឌនៃបមាណីយអន្តរជាតិ និងទៅតាមអ្វីដែលបានរៀបរាប់ខាងលើ។ ដូច្នេះ មិនមានវិធានការណ៍ណាមួយដែលមានលក្ខណៈជាការដាក់ទណ្ឌកម្មទេ និងចេញពីចំនុចនេះ វាក៏មិនមានការរំលោភដល់សិទ្ធិសន្មតជាមុនថាគ្មានទោសដែរ។

ង) សិទ្ធិនៅស្ងៀម

១៣) នៅចុងបញ្ចប់ មានការលើកឡើងថា ការដែលបំបែកជនជាប់ឃុំនៅឱ្យដាច់ចេញពីគ្នា គឺជាការគាបសង្កត់ទៅលើជនត្រូវចោទ ក្នុងគោលបំណងដើម្បីឱ្យពួកគេធ្វើការសហការជាមួយដោយពេញលេញ និងដើម្បីទទួលបានចម្លើយសារភាព។ ទឡ្ហីករណ៍បែបនេះ គឺមិនត្រឹមត្រូវទាល់តែសោះ៖ ជនត្រូវចោទម្នាក់ៗ ពិតជាមានសិទ្ធិក្នុងការនៅស្ងៀមមិនឆ្លើយនឹងសំណួរ ដោយសាររូបគេត្រូវបានសន្មតជាមុនថាគ្មានទោសនៅគ្រប់ដំណាក់កាលនៃការស៊ើបសួរ[14] ហើយមិនថាគោលការណ៍នៃការឃុំខ្លួនបណ្តោះអាសន្ន មិនថារបៀបនៃការឃុំខ្លួន នៅក្នុងករណីនេះ មិនមានទំនាក់ទំនងណាមួយទាល់តែសោះជាមួយនឹងការដែលពួកគេបដិសេធក្នុងការឆ្លើយទៅនឹងសំណួរដែលចោទសួរពួកគេទេ។

---

[13] សូមអានដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្នអ្នកស្រី **អៀង ធីរិទ្ធ៖** កសចស ដីកាឃុំខ្លួនថ្ងៃទី ១៤ ខែវិច្ឆិកា ឆ្នាំ ២០០៧, Doc. No. C21 (ERN 00153250-00153252), លោក **នួន ជា** ៖ កសចស ដីកាឃុំខ្លួនថ្ងៃទី ១៩ ខែកញ្ញា ឆ្នាំ ២០០៧, Doc. No. C9 (ERN 00148717-00148721) និងលោក **អៀង សារី** ៖ កសចស ដីកាឃុំខ្លួនថ្ងៃទី ១៤ ខែវិច្ឆិកា ឆ្នាំ ២០០៧, Doc. No. C22 (ERN 00153284-00153290)។

[14] *Dumont-Maliverg c. France*, nos 57547/00 et 68591/01, § 68, ថ្ងៃទី ៣១ ខែឧសភា ឆ្នាំ ២០០៥។



CO-INVESTIGATING JUDGES * CO-JUGES D'INSTRUCTION * E.C.C.C * C.E.T.C

00191066

ការបក C 33

១៤) ដោយផ្អែកលើចំនុចទាំងអស់នេះហើយ ការហាមឃាត់មិនឲ្យអ្នកជាប់ឃុំមានការប្រាស្រ័យទាក់ទងគ្នាទៅវិញទៅមកនៅរក្សាទុកដដែល លើកលែងតែ **អៀង សារី** និង **អៀង ធីរិទ្ធ** ដូចដែលមានកំណត់នៅក្នុងអនុស្សរណៈរបស់យើងចុះថ្ងៃទី៨ ខែឧសភា ឆ្នាំ ២០០៨ តាមសេចក្តីបញ្ជាក់ដូច្នេះថា ត្រូវបានអនុញ្ញាតយល់ព្រមឲ្យមានការសួរសុខទុក្ខរួមគ្នាជាលក្ខណៈគ្រួសារដល់ពួកគេ ។

## ហេតុដូច្នេះ

- តម្កល់ថា ជនជាប់ឃុំទាំងអស់នៅមន្ទីរឃុំឃាំងរបស់ អ.វ.ត.ក មិនមានសិទ្ធិក្នុងការប្រាស្រ័យទាក់ទងគ្នាទៅវិញទៅមកទេ
- សម្រេចលើកលែងចំពោះជនជាប់ឃុំ **អៀង សារី** និង **អៀង ធីរិទ្ធ** ដូចដែលមានកំណត់នៅក្នុងអនុស្សរណៈរបស់យើងចុះថ្ងៃទី៨ ខែឧសភា ឆ្នាំ ២០០៨ ដោយបញ្ជាក់ថា ការសួរសុខទុក្ខរួមគ្នាជាលក្ខណៈគ្រួសារត្រូវបានអនុញ្ញាតយល់ព្រមដល់ពួកគេ ។

ធ្វើនៅភ្នំពេញ ថ្ងៃទី ២០ ខែឧសភា ឆ្នាំ ២០០៨

**សហចៅក្រមស៊ើបអង្កេត**

Co- Investigating Judges

Co-juges d'instruction

MARCEL Lemonde

យូ ប៊ុនឡេង

ដីកាសម្រេចនេះតាក់តែងឡើងជាភាសាខ្មែរ និង ភាសាបារាំង និង បកប្រែជាភាសាអង់គ្លេសជាក្រោយ។

យើង បានប្រគល់ដីកានេះដល់ឈ្មោះខាងក្រោមនៅថ្ងៃទី........ខែ.......... ឆ្នាំ..........

**ជនត្រូវចោទ មេធាវីជនត្រូវចោទ សហព្រះរាជអាជ្ញា ការិយាល័យរដ្ឋបាល អ្នកប្រគល់**

តាមរយៈការជូនដំណឹងនេះ ជនត្រូវចោទ ត្រូវបានប្រាប់ថា:

- ជនត្រូវចោទអាចប្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកានេះ ស្របតាមលក្ខណ្ឌដែលមានចែងក្នុងវិធាន ៧៥ នៃវិធានផ្ទៃក្នុង នៃអង្គជំនុំជម្រះវិសាមញ្ញ ។
- នៅគ្រប់ករណីទាំងអស់ ជនត្រូវចោទ មានសិទ្ធិត្រូវបាននាំខ្លួនទៅជួបសហចៅក្រមស៊ើបអង្កេត យ៉ាងហោចណាស់រៀងរាល់ ១២០ ថ្ងៃម្តង ហើយ ត្រូវផ្តល់ឱកាសដើម្បីពិភាក្សាអំពីប្រព្រឹត្តិកម្ម និង លក្ខខ័ណ្ឌនៃការឃុំខ្លួន ។
- នៅពេលជួបសហចៅក្រមស៊ើបអង្កេត ជនត្រូវចោទ អាចធ្វើការស្នើសុំផ្សេងៗ ហើយ សហចៅក្រមស៊ើបអង្កេត ត្រូវសម្រេចអំពីសំណើរនេះ។
- ជនត្រូវចោទ អាចធ្វើការកត់សម្គាល់ មុនពេលដែលសហចៅក្រមស៊ើបអង្កេត សម្រេចអំពីការបន្តការឃុំខ្លួន ជនត្រូវចោទនេះ។ ជនត្រូវចោទ អាចប្តឹងឧទ្ធរណ៍ប្រឆាំងនឹងសេចក្តីសម្រេចនេះ។
- ក្នុងពេលឃុំខ្លួនបណ្តោះអាសន្ន ជនត្រូវចោទ ឬមេធាវីរបស់គេ អាចធ្វើសំណើសុំដោះលែងទៅសហចៅក្រមស៊ើបអង្កេតបានគ្រប់ពេលវេលា ។
- បើស្ថានភាពផ្លាស់ប្តូរក្រោយពេលដាក់ពាក្យសុំចុងក្រោយ ជនត្រូវចោទ អាចដាក់ពាក្យសុំនៅក្រៅឃុំសាជាថ្មីម្តងទៀត ក្នុងរយៈពេលមិនឱ្យតិចជាង ៩០ថ្ងៃ បន្ទាប់ពីសេចក្តីសម្រេចចុងក្រោយលើពាក្យសុំដោះលែងនៅក្រៅឃុំពីពេលមុន។